# សមិទ្ធផលវិស័យធនធានទឹក និងឧតុនិយម
# ចុងអាណត្តិទី ២ និងដើមអាណត្តិទី ៣ នៃរដ្ឋសភា
# ( ភាគ ៣ )













**ប្រសាសន៍សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងពិធីសម្ពោធជាផ្លូវការអាងទឹកតាមោក ស្រុកពញាឮ ខេត្តកណ្តាលនាថ្ងៃទី ៨ ខែ មករា ឆ្នាំ ២០០៥**

"ឥឡូវគិតចែកអាណត្តិនេះ ឯកឧត្តម គាត ឈន់ សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ និងខ្ញុំ ឯកភាពគ្នាថា ប្រកាសថាៈ រដ្ឋាភិបាលអាណត្តិនេះ គឺរដ្ឋាភិបាលធារាសាស្ត្រ រដ្ឋាភិបាលអាណត្តិទីពីរ គឺរដ្ឋាភិបាលផ្លូវថ្នល់ ៗ រដ្ឋាភិបាលអាណត្តិនេះ គឺរដ្ឋាភិបាលធារាសាស្ត្រ អញ្ចឹងទេ ខ្ញុំប្រាប់ឯកឧត្តម លឹម គានហោ ហើយថា លើកគំរោងមកគំរោងដែលជាជំនួយអន្តរជាតិ អាហ្នឹង យើងអភិវឌ្ឍន៍តាមជំនួយអន្តរជាតិ ឬកម្ចី ប៉ុន្តែគំរោងណា ដែលខ្ញុំចង្អុល ដូចជាឈ្វាំង ឥឡូវគ្រឿងចក្រចុះដល់ កន្លែងណាទៀតដែលខ្ញុំចង្អុល ដាក់ទៅលើ ប៉ុន្មានឆ្នាំចុងក្រោយគឺថា យើងដោះស្រាយបាន បើយើងមិនចាប់ផ្តើមដំណើរការពី ពីទឹកទេ យើងមិនអាចធ្វើអោយសេដ្ឋកិច្ចរបស់យើងស្ទុះរួចទេ ឆ្នាំណាក៏ឆ្នាំខ្វះទឹក ឆ្នាំណា ក៏ប៉ះជំនន់ ឆ្នាំណាក៏ វាមានកន្លែងនេះ កន្លែងនោះ ៗ"

# លិខិតថ្វាយព្រះពរ និងជូនពរ

ទូលព្រះបង្គំ យើងខ្ញុំ

ជាមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ នៃ

ក្រសួងធនធានទឹក និងឧតុនិយម

ន.ព.ឯ.ក AIDOC
Code: 157-006
Date:
Donated by:

សូម

ក្រាបបង្គំទូលថ្វាយ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
ព្រះមហាវីរៈក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ
និងសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ
ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

ក្រាបបង្គំទូលថ្វាយ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ នូវ
មនោសញ្ចេតនា ប្រកបដោយកតញ្ញូកតវេទិតាធម៌យ៉ាងស្មោះស្ម័គ្របំផុត
និងសូមព្រះរាជានុញ្ញាតថ្វាយនូវព្រះរាជសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល
វិបុលសុខ ព្រះរាជសុខភាពមាំមួន ព្រះជន្មាយុយឺនយូរ ជាងរយព្រះវស្សា

សូមថ្វាយព្រះពរ និងជូនពរ

សម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រិយ៍ លោកជំទាវ ឯកឧត្តម
អ្នកឧកញ៉ា លោក លោកស្រី សូមជួបតែនឹងពុទ្ធពរទាំងបួនប្រការ គឺ
អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈកុំបីឃ្លៀងឃ្លាតឡើយ

ឯកឧត្តម **លឹម គានហោ**

រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

ព្រមទាំងមន្ត្រីរាជការទាំងអស់ក្រោមឱវាទ

# អារម្ភកថា

ក្នុងរយៈពេល២អាណត្តិកន្លងមកនេះ រាជរដ្ឋាភិបាលបានដាក់ទិសដៅពីសំខាន់ៗគឺការកាត់បន្ថយភាពក្រីក្រ និងយុទ្ធសាស្ត្រចតុកោណដល់ក្រសួង និងស្ថាប័ននានាអនុវត្តន៍ដើម្បីធានាសុវត្ថិភាពស្បៀងដល់ប្រជាជនកម្ពុជា ។ ជាក់ស្តែងថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងធនធានទឹក និងឧតុនិយម បានខិតខំយកអស់កំលាំងកាយចិត្ត ក្នុងការបំពេញភារកិច្ចដោយទទួលបានសមិទ្ធផលល្អគួរជាទីមោទនៈ ។ សៀវភៅដែលបង្ហាញនូវសមិទ្ធិផលវិស័យធនធានទឹក និងឧតុនិយមចុងអាណត្តិទី ២ និងដើមអាណត្តិទី ៣ នៃរដ្ឋសភា ភាគ៣ បានប្រមូលនូវប្រព័ន្ធសំណង់តូច ធំ សំខាន់ៗរបស់ក្រសួងក្នុងពេលកន្លងមកក្រោមការដឹកនាំដ៏ឈ្លាសវៃ និងមានសម្ថភាពខ្ពស់របស់ឯកឧត្តម **លឹម គានហោ** ដែលជានិច្ចជាកាលតែងតែយកចិត្តទុកដាក់លើបញ្ហាទឹកដែលជាកត្តាលីករដ៏សំខាន់សំរាប់អភិវឌ្ឍន៍លើគ្រប់វិស័យ ពិសេសជំរុញវិស័យកសិកម្មនៅប្រទេសកម្ពុជា អោយមានការរីកចំរើនថែមទៀត ស្របតាមពាក្យថា ទឹកជាមាស (ស) ។ នេះបង្ហាញអោយឃើញយ៉ាងប្រត្យក្សថា ក្រសួងធនធានទឹក និងឧតុនិយម បានឆ្លើយតបទៅនឹងភារកិច្ចដ៏ឧត្តុងឧត្តម ដែលសម្តេច **ហ៊ុន សែន** ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានប្រគល់ជូន។

ទន្ទឹមនឹងនេះក្រសួងធនធានទឹក និងឧតុនិយម សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកក់ក្តៅជាទីបំផុតចំពោះស្ថាប័នជាតិ និងអន្តរជាតិនានា ដែលបានជួយឧបត្ថម្ភគាំទ្រ និងមានកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរ ធ្វើអោយសំរេចបាននូវសមិទ្ធផលដ៏ត្រចះត្រចង់គួរជាទីមោទនៈនេះឡើង។

# ពិធីចុះហត្ថលេខា ស្តីពីការទទួលជំនួយ ឥតសំណងពីរាជរដ្ឋាភិបាលជប៉ុន



នាថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៥ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា បានចូលរួមជាអធិបតីភាពក្នុងពិធីចុះហត្ថលេខា ស្តីពីការផ្តល់ ជំនួយ ឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុនជិត ៤០ លានដុល្លាសហរដ្ឋអាមេរិក ដល់រាជរដ្ឋាភិបាលកម្ពុជា

# ពិធីប្រគល់-ទទួលអុិចស្កាវ៉ាទ័រចំនួន ២០ គ្រឿង ដែលជាជំនួយឥតសំណង របស់សាធារណរដ្ឋប្រជាមានិតចិន








ឯកឧត្តមរដ្ឋមន្ត្រី **លឹម គានហោ** និង ឯកឧត្តមឯកអគ្គរដ្ឋទូតចិន ថ្លែងសុន្ទរកថាក្នុងឱកាសពិធីប្រគល់-ទទួលអុិចស្កាវ៉ាទ័រ

ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងឯកឧត្តមឯកអគ្គរដ្ឋទូតចិន ចុះហត្ថលេខាលើពិធីសារ ស្តីពីការប្រគល់-ទទួលអុិចស្កាវ៉ាទ័រ ចំនួន ២០ គ្រឿង





ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ទទួលសោតំណាងអ៊ិចស្កាវ៉ាទ័រ ចំនួន ២០ គ្រឿង ពីឯកឧត្តមឯកអគ្គរដ្ឋទូតចិន



ឯកឧត្តមរដ្ឋមន្ត្រី **លឹម គានហោ** និងឯកឧត្តមឯកអគ្គរដ្ឋទូតចិន អញ្ជើញទស្សនាអ៊ិចស្កាវ៉ាទ័រ ចំនួន ២០ គ្រឿង ដែលជាជំនួយឥតសំណងរបស់សាធារណរដ្ឋប្រជាមានិតចិន



**អ៊ិចស្កាវ៉ាទ័រចំនួន ២០ គ្រឿង ដែលជាជំនួយឥតសំណងរបស់សាធារណរដ្ឋប្រជាមានិតចិន**

# ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ អាងទឹកតាមោក




*សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា បានអញ្ជើញចូលរួមក្នុងពិធីសម្ពោធ ជាផ្លូវការ អាងទឹកតាមោក ស្រុកពញាឮ ខេត្តកណ្តាល*

អាងទឹក **តាមោក** ស្ថិតនៅក្នុង ស្រុកពញាឮ ខេត្តកណ្តាល មានចំងាយប្រមាណ ១២ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ តាមបណ្តោយផ្លូវជាតិលេខ ៥ ។ ជារៀងរាល់ឆ្នាំក្នុងរដូវវស្សាក្នុងអំឡុងពេលដែលមានទឹកជំនន់ទន្លេមេគង្គឡើងខ្លាំង ធារទឹកមួយផ្នែកធំបានហូរចាក់ចូលក្នុងបឹងទន្លេសាប, ចូលទៅសមុទ្រចិនភាគខាងត្បូងតាមរយៈទន្លេបាសាក់ និងទន្លេមេគង្គក្រោម ហើយមួយផ្នែកទៀតបានហូរទៅកាន់តំបន់ទំនាប បឹងបួរនានា ដែលនៅជុំវិញបឹងទន្លេសាប ។ ក្នុងពេលជាមួយគ្នានេះអាងទឹក **តាមោក** ដែលស្ថិតក្នុងផ្ទៃរងទឹកជំនន់បឹងទន្លេសាប ក៏បានទទួលនូវការហូរចាក់បំពេញពីទឹកជំនន់នេះផងដែរ ។ ដោយសារតែឥទ្ធិពលពីទឹកជំនន់នេះ ហើយទើបនៅឆ្នាំ ១៩៨០ អតីតរដ្ឋកម្ពុជាបានប្រែក្លាយអាងទឹក **តាមោក** នេះទៅជាហេដ្ឋារចនាសម្ព័ន្ធ ធារាសាស្ត្រ សំរាប់ស្តុកទឹកក្នុងរដូវទឹកជំនន់ ដើម្បីបំរើដល់ការស្រោចស្រពស្រូវរដូវប្រាំង ជូនប្រជាកសិករ បានប្រមាណ១៩០០ ហិកតា ដែលស្ថិតនៅជុំវិញអាង ។ ប៉ុន្តែដោយថវិកាជាតិនៅពេលនោះ នៅមានកំរិត និងមានទឹកជំនន់ធំៗជាប់ៗគ្នាក្នុងប៉ុន្មានឆ្នាំ កន្លងមកនេះ បានធ្វើអោយហេដ្ឋារចនាសម្ព័ន្ធអាងទាំងមូលរងនូវការខូចខាតជាច្រើន។ ដោយស្របតាមយុទ្ធសាស្ត្រ របស់រាជរដ្ឋាភិបាល លើការស្តារ និងការកសាង ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ ស្ថិតនៅក្នុងមុំទី ២ នៃយុទ្ធសាស្ត្រចតុកោណ របស់រាជ